# ជីវិតថ្មីរបស់បងប្អូន

# Your New Life



កម្មវិធីជីវិតគ្រិស្តបរិស័ទ

# ជីវិតថ្មីរបស់បងប្អូន

# Your New Life

ការបោះពុម្ពលើកទី១១

Eleventh edition

ដោយ L. Jeter Walker

GLOBAL UNIVERSITY

Address of the Global University office in your area:

Cambodia Bible Institute (CBI) - Christian Life Program
#37M, St. 16, Sangkat Toeuk Thla,
Khan Sen Sok, Phnom Penh, CAMBODIA

Global University - Battambang CAM Office
Salaa Hope - AOG
Phom Romcheck 4, Khum Ratanak
Srok Battambang
Battambang, CAMBODIA

Developed in cooperation with Global University staff

School for Evangelism and Discipleship
Global University
1211 South Glenstone
Springfield, MO 65804
USA

Translated from the Eleventh edition, 2007 (English)
First edition 2018 (Khmer)
©2018 Global University
All rights reserved
Khmer: *Your New Life* by L. Jeter Walker

Unless otherwise indicated, Scripture is taken from the Khmer Standard Version ©2005 United Bible Societies. Used by permission.

PN 11.13

www.globaluniversity.edu
www.globalreach.org (free pdf downloads)

Khmer version by Cambodia Bible Institute (CBI) Translation Office
Project Editor: Darin Clements
Head Translator: គឹម ឡុងឌី (Kim Longdi)
Translation Staff:
កែន សោភ័ណ្ឌ (Ken Sophorn)
ឈួន ស្រីទូច (Chhoun Srey Touch)
មុំ រ៉ាវី (Mom Ravee)
យត សៃអុីម (Yoat Sayim)
ស៊ុន ប៊ុននី (Sun Bunny)
ហ៊ុយ សាម៊ី (Hoy Samey)
Additional Proofreading: រៀល ណាឡេង (Real Naleng)
Cover Design: ឆាត វាសនា (Chhat Veasna)

# មាតិកា


បុព្វកថា.....6
កម្មវិធីជីវិតគ្រិស្តបរិស័ទ.....7
មុនពេលអ្នកចាប់ផ្តើម.....8

## ជំពូកទី១

១ អ្នកបានចាប់ផ្តើមជីវិតថ្មី You Have Begun a New Life.....17
២ អ្នកកំពុងតែរៀនដើរ You Are Learning to Walk.....27
៣ ព្រះបិតារបស់អ្នកកំពុងតែមានព្រះបន្ទូលមកកាន់អ្នក Your Father Is Speaking to You.....39
៤ តើអ្នកចង់រីកចម្រើនដែរឬទេ? Do You Want to Grow?.....51
៥ ជីវិតថ្មី: សកម្មភាពថ្មីៗ New Life, New Activities.....61

## ជំពូកទី២

៦ ខ្នាតគំរូថ្មីរបស់អ្នក Your New Standards.....79
៧ អ្នកមានព្រះដ៏ជួយការពារមួយ You Have a Helper.....87
៨ ជីវិតរបស់អ្នកជាពន្លឺ Your Life Is a Light.....97
៩ របៀបដែលមានគ្រួសារមានសុភមង្គល How to Have a Happy Home.....109
១០ សេរីភាពថ្មីរបស់អ្នក Your New Freedom.....121

## ការវាយតម្លៃតាមជំពូក

ការវាយតម្លៃជំពូកទី១.....135
ការវាយតម្លៃជំពូកទី២.....141
ពាក្យពេចន៍ចុងក្រោយ.....147

## កម្មវិធីជីវិតគ្រិស្តបរិស័ទ The Christian Life Series

**ជីវិតថ្មីរបស់បងប្អូន Your New Life**

ព្រះគម្ពីររបស់បងប្អូន Your Bible

ព្រះយេស៊ូជានរណា Who Jesus Is

ក្រុមជំនុំ The Church

ការផ្សព្វផ្សាយដំណឹងល្អដោយខ្លួនឯងផ្ទាល់ Personal Evangelism

ក្រមសីលធម៌តាមព្រះគម្ពីរ Bible Ethics

នៅពេលបងប្អូនអធិស្ឋាន When You Pray

របៀបសិក្សាព្រះគម្ពីរ How to Study the Bible

ព្រះដ៏ជួយការពាររបស់បងប្អូន Your Helpful Friend

ការថ្វាយបង្គំរបស់គ្រិស្តបរិស័ទ Christian Worship

អ្នកបម្រើព័ន្ធកិច្ចជាគ្រិស្តបរិស័ទ Christian Workers

អាពាហ៍ពិពាហ៍ និងគ្រួសារ Marriage and the Home

គម្រោងការរបស់ព្រះជាម្ចាស់—ជម្រើសរបស់បងប្អូន God’s Design—Your Choice

ដំណឹងល្អរៀបរៀងដោយលោកយ៉ូហាន John’s Gospel

យើងជឿ We Believe

ភារកិច្ចរបស់ក្រុមជំនុំ What Churches Do

ព័ន្ធកិច្ចនៃការបង្រៀន The Teaching Ministry

គ្រិស្តបរិស័ទនៅក្នុងសហគមន៍ The Christian in the Community

# បុព្វកថា

នៅពេលដែលអ្នកទូលសូមព្រះយេស៊ូគ្រិស្តឱ្យធ្វើជាព្រះសង្គ្រោះរបស់អ្នក ព្រឹត្តិការណ៍ដ៏អស្ចារ្យមួយបានកើតឡើង ព្រះអង្គបាននាំអ្នកចេញពីទីងងឹតមកកាន់ពន្លឺ។ អំពើបាបរបស់អ្នកត្រូវបានលើកលែងទោសឱ្យហើយអ្នកបានមកចូលរួមក្នុងគ្រួសាររបស់ព្រះជាម្ចាស់។ អ្នកបានទទួលជីវិតថ្មី។ សៀវភៅនេះសរសេរអំពីជីវិតថ្មីនោះដែលអ្នកបានទទួលដោយសារអ្វីដែលព្រះយេស៊ូបានធ្វើចំពោះអ្នក។

ជីវិតថ្មីរបស់អ្នកជាព្រះអំណោយទានផ្ទាល់មកពីព្រះបិតារបស់អ្នកនៅស្ថានបរមសុខ។ ជីវិតថ្មីនេះនឹងស្ថិតនៅជាមួយអ្នកជារៀងរហូត! ទោះបីជីវិតនេះមកពីព្រះជាម្ចាស់ដែលគង់នៅស្ថានបរមសុខក៏ដោយ ក៏អ្នកអាចចាប់ផ្តើមរស់នៅតាមជីវិតថ្មីនោះនៅលើផែនដីនៅពេលឥឡូវនេះបានដែរ។ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់នឹងផ្លាស់ប្រែអ្នកបន្តិចម្តងៗរហូតដល់អ្នកមានលក្ខណៈដូចព្រះអង្គ។ ចរិត និងទម្លាប់ចាស់របស់អ្នកនឹងរសាត់បាត់ទៅ នៅពេលអ្នកស្តាប់បង្គាប់ព្រះអង្គ។ ខ្នាតគំរូថ្មីដែលល្អប្រសើរនឹងកកើតឡើងជាមិនខាន ។

តើអ្វីៗទាំងអស់នេះនឹងកើតឡើងយ៉ាងដូចម្តេច? តើអ្នកនឹងគិតយ៉ាងម៉េច ដោយសារតែឥឡូវនេះអ្នកក្លាយជាកម្មសិទ្ធរបស់ព្រះជាម្ចាស់? តើនឹងមានអ្វីខុសប្លែក? តើព្រះបិតារបស់អ្នកនៅស្ថានបរមសុខសព្វព្រះហឫទ័យឱ្យអ្នករស់នៅយ៉ាងដូចម្តេច? តើព្រះអង្គប្រាប់អ្នកយ៉ាងណាពីអ្វីដែលព្រះអង្គសព្វព្រះហឫទ័យចង់ឱ្យអ្នកធ្វើ? តើព្រះអង្គប្រទានជំនួយប្រភេទណាខ្លះដល់អ្នក? មុខវិជ្ជានេះត្រូវបានសរសេរឡើងដើម្បីឆ្លើយសំណួរទាំងនេះ។ អ្នកនឹងរកឃើញសេចក្តីពិតដ៏សំខាន់អំពីជីវិតថ្មីដែលព្រះជាម្ចាស់បានប្រទានដល់អ្នកមិនខាន ។

# កម្មវិធីជីវិតគ្រិស្តបរិស័ទ

## The Christian Life Series

*ជីវិតថ្មីរបស់អ្នកប្អូន* ជាមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាចំនួន១៨ក្នុងកម្មវិធីបង្កើតសិស្ស សម្រាប់អ្នកទើបនឹងជឿ។ កម្មវិធីជីវិតគ្រិស្តបរិស័ទជាការសិក្សាដើម្បីជួយសិស្សឱ្យរីកចម្រើនក្នុងទំនាក់ទំនងរបស់ពួកគេជាមួយព្រះគ្រិស្តសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងយល់ដឹងអំពីគោលបំណងរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់ពួកគេកាន់តែប្រសើរជាងមុន។

សិស្សនឹងសិក្សាប្រធានបទគ្រិស្តបរិស័ទជាមូលដ្ឋាននៅក្រោមផ្ទៃរឿងចំនួនប្រាំមួយ។ មុខវិជ្ជានីមួយៗមានលក្ខណៈជាកិច្ចសន្ទនា និងងាយស្រួលអាន។ តារាងខាងក្រោមបកស្រាយអំពីរបៀបដែលវគ្គនៃការសិក្សាត្រូវបានរៀបចំសម្រាប់កម្មវិធីជីវិតគ្រិស្តបរិស័ទ។

| | វគ្គទី១<br>**Unit One** | វគ្គទី២<br>**Unit Two** | វគ្គទី៣<br>**Unit Three** |
|---|---|---|---|
| ជីវិតខាងព្រលឹងវិញ្ញាណ<br>**Spiritual Life** | ជីវិតថ្មីរបស់បងប្អូន<br>Your New Life | នៅពេលបងប្អូនអធិស្ឋាន<br>When You Pray | គម្រោងការរបស់ព្រះជាម្ចាស់-ជម្រើសរបស់បងប្អូន<br>God's Design—Your Choice |
| ព្រះគម្ពីរ<br>**The Bible** | ព្រះគម្ពីររបស់បងប្អូន<br>Your Bible | របៀបសិក្សាព្រះគម្ពីរ<br>How to Study the Bible | ដំណឹងល្អរៀបរៀងដោយលោកយ៉ូហាន<br>John's Gospel |
| ទេវវិទ្យា<br>**Theology** | ព្រះយេស៊ូជានរណា<br>Who Jesus Is | ព្រះដ៏ជួយការពាររបស់បងប្អូន<br>Your Helpful Friend | យើងជឿ<br>We Believe |
| ក្រុមជំនុំ<br>**The Church** | ក្រុមជំនុំ<br>The Church | ការថ្វាយបង្គំរបស់គ្រិស្តបរិស័ទ<br>Christian Worship | ភារកិច្ចរបស់ក្រុមជំនុំ<br>What Churches Do |
| កិច្ចបម្រើ<br>**Service** | ការផ្សព្វផ្សាយដំណឹងល្អដោយខ្លួនឯងផ្ទាល់<br>Personal Evangelism | អ្នកបម្រើព័ន្ធកិច្ចជាគ្រិស្តបរិស័ទ<br>Christian Workers | ព័ន្ធកិច្ចនៃការបង្រៀន<br>The Teaching Ministry |
| ក្រមសីលធម៌របស់គ្រិស្តបរិស័ទ<br>**Christian Ethics** | ក្រមសីលធម៌តាមព្រះគម្ពីរ<br>Bible Ethics | អាពាហ៍ពិពាហ៍និងគ្រួសារ<br>Marriage and the Home | គ្រិស្តបរិស័ទនៅក្នុងសហគមន៍<br>The Christian in the Community |

# មុនពេលអ្នកចាប់ផ្តើម

## របៀបប្រើសៀវភៅនេះ

សៀវភៅនេះ ត្រូវបានបែងចែកជាមេរៀនជំនួសឱ្យជំពូក។មេរៀននីមួយៗ ចាប់ផ្តើមដោយទំព័រសំខាន់ៗចំនួនពីរ។ នៅបន្ទាប់ពីលេខនៃមេរៀននីមួយៗមានចំណងជើងនិងសេចក្តីផ្តើមខ្លីនៃមេរៀន។នៅទំព័របន្ទាប់ជា ***គម្រោង***សម្រាប់មេរៀន។ វាជាកំណត់ត្រាពីអ្វីដែលអ្នកអាចរំពឹងនឹងសិក្សានៅក្នុងមេរៀននេះ។

បន្ទាប់មកទៀត ជាគោលដៅនៃមេរៀន។ ***គោលដៅ*** គឺជាសេចក្តីណែនាំអំពីអ្វីដែលអ្នកគួរតែអាចធ្វើបន្ទាប់ពីរៀនមេរៀននេះចប់។ សូមអានគោលដៅនីមួយៗដោយយកចិត្តទុកដាក់ដោយពួកវានឹងជួយអ្នកឱ្យផ្តោតទៅលើចំណុចដ៏សំខាន់បំផុតនៃមេរៀននេះ។

ដើម្បីជួយអ្នកឱ្យសម្រេចគោលដៅបាន មេរៀននីមួយៗមានសំណួរ និងសកម្មភាព។ ចំណងជើងរង***លំហាត់អនុវត្តន៍*** ជាសញ្ញាប្រាប់ឱ្យអ្នកឆ្លើយសំណួរអំពីមេរៀនដែលបានរៀនរួចមកហើយ។សូមកុំរំលងផ្នែកនេះ។ ការសរសេរចម្លើយនឹងជួយអ្នក ឱ្យអនុវត្តនូវអ្វីដែលអ្នកបានរៀនរួចហើយ។អ្នកអាចឆ្លើយសំណួរភាគច្រើននៅក្នុងសៀវភៅរបស់អ្នក។ ប្រសិនបើគ្មានកន្លែងទំនេរគ្រប់គ្រាន់ ដើម្បីសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅនេះទេសូមសរសេរចម្លើយទាំងនោះនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកត់ត្រាផ្ទាល់ខ្លួន ដែលអ្នកអាចប្រើដើម្បីរំលឹកមេរៀននៅពេលក្រោយ។

ក្រោយពីឆ្លើយសំណួរ អ្នកអាចផ្ទៀងចម្លើយនៅចុងបញ្ចប់នៃមេរៀនដែលមានៅក្នុងផ្នែក***សូមផ្ទៀងចម្លើយរបស់អ្នក***។ សូមកុំមើលចម្លើយមុន រហូតដល់អ្នកបានសរសេរចម្លើយផ្ទាល់ខ្លួនរបស់អ្នករួចរាល់សិន។ការធ្វើបែបនេះ នឹងជួយឱ្យអ្នកចងចាំអ្វីដែលអ្នកបានសិក្សាកាន់តែប្រសើរឡើង។សូមកែចម្លើយទាំងឡាយ ដែលអ្នកឆ្លើយមិនទាន់បានត្រឹមត្រូវ។ ចម្លើយទាំងនោះមិនបានរៀបតាមលំដាប់លំដោយទេ ដូច្នេះ អ្នកនឹងមិនងាយនឹងមើលឃើញចម្លើយចំពោះសំណួរបន្ទាប់ឡើយ។

## របៀបឆ្លើយសំណួរសិក្សា

មុខវិជ្ជានេះ ប្រើសំណួរប្រភេទផ្សេងៗគ្នាជាច្រើន។នៅខាងក្រោមនេះ មានគំរូនៃប្រភេទសំណួរទូទៅចំនួនបីនិង របៀបនៃការឆ្លើយសំណួរទាំងនោះ។

### សំណួរពហុជ្រើសរើស

សំណួរពហុជ្រើសរើសចង់ឱ្យអ្នកជ្រើសរើសចម្លើយមួយពីបណ្តាចម្លើយដែលគេបានផ្តល់ឱ្យ។

*ឧទាហរណ៍*

១. ព្រះគម្ពីរមានសរុបទាំងអស់

ក) ១០០កណ្ឌ។

ខ) ៦៦កណ្ឌ។

គ) ២៧កណ្ឌ។

ចម្លើយត្រឹមត្រូវគឺ ខ)៦៦កណ្ឌ។ ក្នុងសៀវភៅមគ្គុទេសក៍សិក្សារបស់អ្នក ចូរគូសរង្វង់លើ **ខ)** ដែលបានបង្ហាញនៅខាងក្រោម៖

១. ព្រះគម្ពីរមានសរុបទាំងអស់

ក) ១០០កណ្ឌ។

(ខ) ៦៦កណ្ឌ។

គ) ២៧កណ្ឌ។

### សំណួរខុស/ត្រូវ

សំណួរខុស/ត្រូវ ចង់ឱ្យអ្នកជ្រើសរើសយកប្រយោគណាដែល**ត្រឹមត្រូវ**។

*ឧទាហរណ៍*

២. តើប្រយោគណាដែលត្រឹមត្រូវ?

ក) ព្រះគម្ពីរមាន ១២០ កណ្ឌ។

(ខ) ព្រះគម្ពីរជាព្រះរាជសារសម្រាប់អ្នកជឿនៅសព្វថ្ងៃនេះ។

គ) អ្នកនិពន្ធព្រះគម្ពីរទាំងអស់បានសរសេរជាភាសាហេប្រឺ។

(ឃ) ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឱ្យតែងព្រះគម្ពីរ។

ប្រយោគ **ខ)** និង **ឃ)** ត្រឹមត្រូវ។ អ្នកគួរតែគូសរង្វង់ជុំវិញអក្សរទាំងពីរនេះដើម្បីបង្ហាញជម្រើសរបស់អ្នក ដូចអ្នកបានឃើញនៅខាងលើ។

**សំណួរផ្គូផ្គង**

សំណួរផ្គូផ្គងចង់ឱ្យអ្នកផ្គូផ្គងអ្វីដែលស្របគ្នាដូចជាឈ្មោះជាមួយការពណ៌នា ឬកណ្ឌគម្ពីរជាមួយអ្នកនិពន្ធ។

*ឧទាហរណ៍*

៣. ចូរសរសេរលេខសម្រាប់ឈ្មោះអ្នកដឹកនាំ(ខាងស្តាំ) នៅខាងមុខឃ្លានីមួយៗ ដែលពណ៌នាអំពីអ្វីដែលគាត់ធ្វើ (ខាងឆ្វេង)។

…១….ក) បានទទួលបទបញ្ញានៅភ្នំស៊ីណៃ　　　　　　　　១) ម៉ូសេ

…២….ខ) បានដឹកនាំជនជាតិអ៊ីស្រាអែលឆ្លងកាត់ទន្លេយ័រដាន់　　　២) យ៉ូស្វេ

…២….គ) បានដើរជុំវិញក្រុងយេរីខូ

…១….ឃ) បានរស់នៅក្នុងដំណាក់របស់ស្តេចផារ៉ោន

ឃ្លា **ក)** និង **ឃ)** និយាយអំពី*ម៉ូសេ*ហើយឃ្លា **ខ)** និង **គ)** និយាយអំពី*យ៉ូស្វេ*។ អ្នកគួរតែសរសេរលេខ **១** នៅពីមុខ **ក)** និង **ឃ)** ហើយសរសេរលេខ **២** នៅពីមុខ **ខ)** និង **គ)** ដូចអ្នកបានឃើញនៅខាងលើ។

## ពាក្យណែនាំសម្រាប់ការសិក្សា

១. សូមញែកពេលស្ងាត់ស្ងៀម និងពេលវេលាទៀងទាត់សម្រាប់ការសិក្សារបស់អ្នក។វានឹងងាយស្រួលផ្ចង់អារម្មណ៍ជាង ប្រសិនបើការសិក្សារបស់អ្នក ជាផ្នែកមួយនៃទម្លាប់ប្រចាំថ្ងៃនោះ។

២. សូមអធិស្ឋាននៅពេលដែលអ្នកសិក្សាមេរៀននីមួយៗដោយបើកព្រះគម្ពីរ ព្រមទាំងមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយ ហើយតាមរយៈមុខវិជ្ជានេះ អ្នកកំពុងតែស្ថិតនៅក្នុងថ្នាក់រៀនរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ចូរទូលសូមព្រះអម្ចាស់ ដើម្បីជួយឱ្យអ្នកយល់មេរៀននេះនិងអនុវត្តវា នៅក្នុងជីវិតរបស់អ្នក ។

៣. សូមអានសេចក្តីផ្តើមនៃមេរៀន គម្រោងមេរៀន និងគោលដៅដោយយកចិត្តទុកដាក់។

៤. សូមចាប់ផ្តើមអានមេរៀនដោយយកចិត្តទុកដាក់។សូមមើលខគម្ពីរយោង និងសរសេរកំណត់ត្រាដែលអាចមានប្រយោជន៍។ ខគម្ពីរជួយធ្វើឱ្យចំណុចសំខាន់ក្នុងមេរៀននេះកាន់តែមានប្រសិទ្ធភាព។

៥. ចូរឆ្លើយសំណួរសិក្សា នៅក្នុងចន្លោះដែលបានដាក់ជូន។សូមប្រើសៀវភៅសរសេរ ឬសៀវភៅកត់ត្រាផ្ទាល់ខ្លួនរបស់អ្នកនៅពេលចាំបាច់។

៦. សូមគិតអំពីអ្វីដែលអ្នកបានរៀនរួចហើយនិងស្វែងរកវិធីដើម្បីអនុវត្តវានៅក្នុងការពិភាក្សាជាមួយគ្រួសារ និងមិត្តភ័ក្តិ នៅក្នុងការសិក្សាព្រះគម្ពីរ ឬ ក្នុងឱកាសណាមួយ។

៧. សូមរៀនតាមសម្រួល។ គ្មានកណ្តឹងណានឹងរោទ៍ ដើម្បីបង្ខំអ្នកឱ្យសិក្សាមេរៀនថ្មីនោះឡើយ។

## ការវាយតម្លៃតាមជំពូក

នៅចុងបញ្ចប់នៃមុខវិជ្ជានេះអ្នកនឹងឃើញ**ការវាយតម្លៃតាមជំពូក។ ក្រដាសសំណួរចម្លើយ**ត្រូវបានដាក់សញ្ញាសម្គាល់យ៉ាងច្បាស់ សម្រាប់ជំពូកនីមួយៗ។ សូមធ្វើតាមការណែនាំ ដែលបានដាក់ជូនដោយប្រុងប្រយ័ត្ន។អ្នកត្រូវតែបំពេញ ហើយផ្ញើក្រដាសចម្លើយរបស់អ្នក ទៅកាន់គ្រូបង្រៀនរបស់អ្នកសម្រាប់ការកែតម្រូវ។ប្រសិនបើអ្នកមិនបានសិក្សាជាមួយសាកលវិទ្យាល័យគ្លូបបល (Global University) ទេនោះ អ្នកនៅតែទទួលបានផលប្រយោជន៍តាមរយៈការបំពេញការវាយតម្លៃតាមជំពូកដដែល។

## របៀបសិក្សាមុខវិជ្ជានេះ

មុខវិជ្ជានេះត្រូវបានសរសេរឡើង ដើម្បីឱ្យអ្នកអាចសិក្សាវាដោយខ្លួនឯងបាន។យើងចូលចិត្តនិយាយថា គ្រូបង្រៀនគឺនៅក្នុងសៀវភៅនេះ។ ប៉ុន្តែ អ្នកក៏អាចសិក្សាមុខវិជ្ជានេះជាក្រុម ដូចជាក្រុមសិក្សាព្រះគម្ពីរតាមសប្តាហ៍ មជ្ឈមណ្ឌលសិក្សា ក្រុមតាមផ្ទះ និងកម្មវិធីយុវជន។ មុខវិជ្ជានេះ អាចត្រូវបានប្រើដើម្បីជាការទំនាក់ទំនងឬ ជាធនធានសម្រាប់ព័ន្ធកិច្ចពន្ធនាគារ ក៏ដូចជាក្រុមជនជាតិភាគតិច ឬ សហគមន៍ផ្សេងទៀតតាមរយៈកម្មវិធីនេះផងដែរ។អ្នកនឹងឃើញថា ទាំងមាតិកា ទាំងវិធីសាស្ត្រនៃការសិក្សាល្អប្រសើរសម្រាប់គោលបំណងទាំងនេះ។

ប្រសិនបើអ្នកសិក្សាមុខវិជ្ជានេះដោយខ្លួនឯងអ្នកអាចបំពេញកិច្ចការទាំងអស់របស់អ្នកតាមរយៈប្រៃសណីយ៍។ សូមកុំភ្លេចប្រើអាសយដ្ឋាននៃការិយាល័យសាកលវិទ្យាល័យគ្លូបបល (Global University) របស់អ្នក។ ប្រសិនបើអ្នកសិក្សាជាក្រុម ឬ តាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្សសូមឱ្យប្រាកដថាអ្នកធ្វើតាមមេរៀនបន្ថែមដែលគ្រូរបស់អ្នកបានដាក់ឱ្យ។

លើសពីនេះទៅទៀត ក្រុមជំនុំរបស់អ្នកអាចជាដៃគូជាមួយនឹងសាកលវិទ្យាល័យគ្លូបបល (Global University) ដើម្បីបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្សថែមទៀតផង។ សូមចូលមើលគេហទំព័រ www.globaluniversity.edu សម្រាប់ព័ត៌មាន និងជំនួយបន្ថែម។

## វិញ្ញាបនបត្រ

វិញ្ញាបនបត្រជាក្រុម ឬ ផ្ទាល់ខ្លួនម្នាក់ៗ មានសម្រាប់សិស្សដែលបានបញ្ចប់មុខវិជ្ជារបស់យើងដោយជោគជ័យ។ ឧទាហរណ៍ ប្រសិនបើអ្នកកំពុងសិក្សាតាមរយៈការិយាល័យជាតិឬ មជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្ស អ្នកអាចទទួលវិញ្ញាបនបត្រពីគ្រូដែលមកពីសកលវិទ្យាល័យគ្លូបបល (Global University) បាន។ ប្រសិនបើអ្នកសិក្សាផ្ទាល់ខ្លួនអ្នកអាចផ្ញើក្រដាសការវាយតម្លៃតាមជំពូកដែលអ្នកបានបំពេញចប់ទៅកាន់ការិយាល័យតាមតំបន់របស់អ្នក។ការិយាល័យជាតិ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្ស អាចទទួលវិញ្ញាបនបត្រតាមរយៈការិយាល័យអន្តរជាតិឬ តាមរយៈ Gospel Publishing House ក្នុងសហរដ្ឋអាមេរិក។

## សម្រាប់ជំនួយបន្ថែម

បញ្ជីសៀវភៅសម្រាប់ The School for Evangelism and Discipleship (SED), Discipleship Training Center Manual, the Study Center Agreement Form ហើយនឹង SED Order Form អាចយកចេញពីអ៊ីនធឺណេតបាន។ សម្ភារសិក្សាផ្សេងៗដែលអាចរកបានសម្រាប់មុខវិជ្ជានេះរួមបញ្ចូលទាំងកាសែត។

សូមចូលមើលគេហទំព័រ www.globaluniversity.edu និង www.globalreach.org សម្រាប់ជាធនធានបន្ថែម។

## អំពីអ្នកនិពន្ធ

Louise Jeter Walker បានធ្វើការអស់មួយជីវិត ដើម្បីជួយឱ្យមនុស្សយល់ដឹងអំពីសេចក្តីពិតរបស់គ្រិស្តបរិស័ទ។ លោកស្រីទទួលបាន BA និង MA ផ្នែកអប់រំគ្រិស្តបរិស័ទ និងត្រូវបានតែងតាំងជាគ្រូគង្វាលរបស់និកាយក្រុមជំនុំព្រះជាម្ចាស់ (Assemblies of God) (សហរដ្ឋអាមេរិក)។ សៀវភៅ និងឯកសាររបស់លោកស្រី ឆ្លុះបញ្ចាំងអំពីបទពិសោធ ៦២ឆ្នាំ ធ្វើជាបេសកជននៅប្រទេសពេរ៉ូ គុយបា អាមេរិកកណ្តាល ឥណ្ឌាភាគខាងលិច និងបែលស៊ិច។

សូមព្រះជាម្ចាស់ប្រទានពរដល់អ្នក នៅពេលដែលអ្នកចាប់ផ្តើមសិក្សាសៀវភៅ*ជីវិតថ្មីរបស់បងប្អូន*។ សូមឱ្យអ្នកបើកចិត្តចំពោះសេចក្តីពិត នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។